Diversity and Disability Alliance

## ពាក្យនិងគោលគំនិតនានាដែលបានបកប្រែហើយត្រូវបានគេប្រើជាទូទៅក្នុងប្រធានបទស្តីពីការគាំទ្រពីមិត្តភក្តិ

គោលបំណងនៃធនធាននេះគឺដើម្បីផ្តល់នូវការបកប្រែដែលចាប់យកអត្ថន័យពិតប្រាកដនៃការគាំទ្ររបស់មត្តិភក្តិ ក្នុងរបៀបមួយដែលមានលក្ខណៈសមរម្យតាមវប្បធម៌ និងងាយយល់ ។

មនុស្សជាច្រើនមានការលំបាកក្នុងការបកប្រែពាក្យបច្ចុប្បន្ន ដែលពិពណ៌នាពីការគាំទ្រមិត្តភក្តិ ។

1. ការបកប្រែខ្លះគឺមិនត្រឹមត្រូវ មិនច្បាស់លាស់ ឬសំដៅទៅលើពិការភាពក្នុងន័យអវិជ្ជមាន។
2. ពាក្យខ្លះមកពីវប្បធម៌អង់គ្លេស-អូស្រ្តាលី ហើយពិបាកក្នុងការបកប្រែសម្រាប់វប្បធម៌ដែលមិនមានគំនិតស្រដៀងគ្នា ។

នេះអាចនាំឱ្យមានការយល់ច្រឡំសម្រាប់មនុស្សដែលត្រូវការព័ត៌មានជាភាសារបស់ពួកគេផ្ទាល់។

ធនធានរួមមានការបកប្រែ ១៨ ពាក្យ និង គោលគំនិតជា:
- ភាសាសរសេរ៥: ភាសាអារ៉ាប់ ខ្មែរ កូរ៉េ ចិនសាមញ្ញ និងវៀតណាម
- ភាសានិយាយ៦: ភាសាអារ៉ាប់ ចិនកាតាំង ខ្មែរ កូរេ ចិនកុកងឺ និងវៀតណាម

## របៀបដែលធនធាននេះត្រូវបានគេបង្កើតឡើង

ធនធាននេះត្រូវបានបង្កើតឡើងដោយជនដែលមានពិការភាពនិងសមាជិកគ្រួសាររបស់ពួកគេដែលមានបទពិសោធន៍ក្នុងការគាំទ្រមិត្តភក្តិ ។

អង្គការសម្ព័ន្ធភាពដើម្បីភាពចម្រុះក្នុងពិការភាព (Diversity Disability Alliance) បានរៀបចំសិក្ខាសាលាជាមួយមិត្តភក្តិ និងអ្នកបកប្រែ ពីក្រុមភាសានិមួយៗ ។ នៅសិក្ខាសាលាទាំងនេះយើងបានពិភាក្សាពីអត្ថន័យនៃពាក្យនិងគោលគំនិតនិមួយៗ ដើម្បីរកការបកប្រែដ៏ល្អបំផុតសម្រាប់សហគមន៍ ។

ការបកប្រែមានទាំងភាសាផ្លូវការ និងភាសាសាមញ្ញ ហើយរួមបញ្ចូលឧទាហរណ៍ដើម្បីផ្តល់ការពន្យល់បន្ថែម។

ជួនកាលយើងត្រូវបង្កើតការពន្យល់ថ្មី និងការបកប្រែថ្មីៗ ដើម្បីចាប់យកគោលគំនិតស្តីពីគាំទ្រមិត្តភក្តិជាភាសាផ្សេងៗគ្នា ។

## ការប្រើធនធាននេះ

មានវិធីជាច្រើនដែលអ្នកអាចប្រើធនធាននេះ ។ អ្នកអាចអានវាដោយខ្លួនឯង ឬក្នុងក្រុម ។

បើសិនជាអ្នកជាសមាជិកនៃក្រុមគាំទ្រមិត្តភក្តិរួចហើយ  អ្នកអាចប្រើធនធាននេះ ជាប្រធានបទពិភាក្សានៅឯកិច្ចប្រជុំលើកក្រោយរបស់អ្នក។ វាអាស្រ័យទៅលើអ្នកទាំងស្រុង !

ពាក្យនិងគោលគំនិតទាំងនេះនឹងមានការផ្លាស់ប្តូរ ។ ការពិភាក្សារបស់អ្នកនឹងជួយបញ្ចាំងពន្លឺថ្មីលើគំនិតទាំងនេះ និងរកវិធីជាច្រើនទៀតដើម្បីនិយាយអំពីការគាំទ្រពីមិត្តភក្តិជាមួយគ្នា។

បើសិនជាអ្នកចង់បានព័ត៌មានបន្ថែមទៀត អំពីការបង្កើតធនធាននេះ ឬចង់ស្វែងយល់បន្ថែមអំពីការគាំទ្រមិត្តភក្តិ សូមទំនាក់ទំនងមកកាន់ Diversity Disability Alliance ។

Diversity Disability Alliance
ទូរស័ព្ទ: 02 8717 1500
អ៊ីមែល: info@ddalliance.org.au
គេហទំព័រ: www.ddalliance.org.au
ធនធានពាក់ព័ន្ធ
ការណែនាំអំពីការគាំទ្រមិត្តភក្តិ
វីឌីអូគាំទ្រមិត្តភក្តិ:  ៨ វីដេអូ ជា ៦ ភាសា